ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម

# គោលការណ៍ណែនាំ
# ស្តីពី
# ការរៀនសូត្រពីកសិករទៅកសិករ
# និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅទីផ្សារ

# GUIDELINES
# ON
# FARMER-TO-FARMER LEARNING AND LINKAGE AGRICULTURAL PRODUCTS TO MARKET

**រៀបចំដោយ** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)
**ឧបត្ថម្ភដោយ** រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD)

IFAD
Investing in rural people

រាជធានីភ្នំពេញ ខែ វិច្ឆិកា ឆ្នាំ ២០១៨

# អារម្ភកថា

ការផ្សព្វផ្សាយកសិកម្មដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ទេរនូវចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍ថ្មីៗដែលធន់នឹងការប្រែប្រួលអាកាសធាតុ។ ការផ្សព្វផ្សាយនេះរួមចំណែកក្នុងការដោះស្រាយ គ្រោះធម្មជាតិ និងបញ្ហានានាដល់កសិករ និងសហគមន៍កសិកម្ម សំដៅជំរុញការបង្កើនផលិតភាព គុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងបង្កើនប្រាក់ចំណូលគ្រួសារ។

ឯកសារស្ដីអំពី ការរៀនសូត្រពីកសិករទៅកសិករនិងការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅកាន់ទីផ្សារ រៀបចំឡើងដោយអនុលោម តាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាបង្ហាញថា សេវាផ្សព្វផ្សាយកសិកម្មអាចផ្ដល់ដោយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ទីប្រឹក្សាកសិកម្ម សាកលវិទ្យាល័យ មជ្ឈមណ្ឌលបណ្ដុះបណ្ដាល វិទ្យាស្ថានស្រាវជ្រាវ ក្រុមកសិករ សហគមន៍កសិកម្មឬអង្គការកសិករ ស្ថាប័នសាសនា និងវត្តអារាម/ព្រះសង្ឃ ដោយសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រាជធានី ខេត្ត។ យន្តការទាំងនេះ ជាការគាំទ្រសម្របសម្រួល និងផ្សារភ្ជាប់ទំនាក់ទំនងរវាងគ្រប់អ្នកផ្ដល់សេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការអ្នកផលិត និងតម្រូវការទីផ្សារ។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) បានរៀបចំ " **គោលការណ៍ណែនាំ ស្ដីពីការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅកាន់ទីផ្សារ** " នេះឡើងដើម្បីចែករំលែក ពីវិធីសាស្ត្រនិងបទពិសោធន៍ជោគជ័យល្អៗដូចជា ការនាំក្រុមកសិករទៅទស្សនៈកិច្ចកសិករដែលជោគជ័យលើការអនុវត្តធុរកិច្ចកសិកម្ម កសិករដែលជោគជ័យធ្វើការបណ្ដុះបណ្ដាលអំពីធុរកិច្ចកសិកម្មដល់ក្រុមកសិករផ្សេងទៀតដែលមានចំណាប់អារម្មណ៍ និងការភ្ជាប់ទំនាក់ទំនងរវាងអ្នកលក់ធាតុចូលកសិកម្ម អ្នកទិញ សហគមន៍កសិកម្ម និងអង្គការកសិករ។

ឯកសារនេះបានរៀបចំជាសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកផ្សព្វផ្សាយបច្ចេកទេសកសិកម្ម មកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង១១ខេត្តនៃកម្មវិធីASPIRE។

អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមដាក់ចេញនូវ" **គោលការណ៍ណែនាំ ស្ដីពីការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្ម** " ដែលជាឯកសារគ្រឹះសម្រាប់មន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកទេសកសិកម្មថ្មីៗ វិធីសាស្ត្រ ការផ្លាស់ប្ដូរនូវបទពិសោធន៍ ការចែករំលែកចំណេះដឹង និងនាំមកនូវកំណើនផលិតកម្មកសិកម្ម ជម្រុញឲ្យមានស្ថិរភាពសេដ្ឋកិច្ចគ្រួសារកសិករ សម្រួលដល់កសិករក្នុងការសម្របខ្លួនតាមស្ថានភាពវិវត្តនៃសាកលភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម បន្សាំ និងការប្រែប្រួលអាកាសធាតុ រួមចំណែកក្នុងការផ្គត់ផ្គង់ផលិតផលកសិកម្មនៅលើទីផ្សារប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ សុក្រ ៤ រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី...៣០.....ខែ...វិច្ឆិកា.....ឆ្នាំ២០១៨

**អគ្គនាយកដ្ឋានកសិកម្ម**

# មាតិកា

ទំព័រ


១. សេចក្តីផ្តើម ........ 1

២. គោលបំណង ........ 1

៣. លទ្ធផលរំពឹងទុក ........ 1

៤. គោលការណ៍គ្រឹះ នៃការរៀនសូត្រពីកសិករទៅកសិករ ........ 2

៥. ការណែនាំ នឹងនិតិវិធី ស្តីពីការរៀនសូត្រពីកសិករទៅកសិករ ........ 2

៦. ចរិកលក្ខណៈ នៃការរៀនសូត្រពីកសិករទៅកសិករ ........ 2

៧. ជំហាននៃការអនុវត្តន៍ ........ 3

៧.១. ជ្រើសរើសកសិករគំរូ ( Demo Farmer ) ........ 3

៧.២. បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពកសិករគំរូ ........ 4

៧.៣. ការជ្រើសរើសកសិករឆ្នើម ( Elite/Outstanding Farmers/Champion Farmer ) ១នាក់/ឃុំ ឬ ១នាក់/ភូមិ.... 4

៧.៤. បណ្តុះបណ្តាលកសិករឆ្នើម ក្លាយជាកសិករគ្រូ ( TOT Champion farmer to became a Farmer Trainer ). 5

៧.៥. ការបង្កើតបណ្តាញកសិករ ........ 6

៨. សកម្មភាពសិក្សាពីកសិករទៅកសិករ ........ 8

៩. តួនាទី និងភារកិច្ច ........ 9

១០. ការតាមដាន និងវាយតម្លៃ ........ 12

១១. សេចក្តីសន្និដ្ឋាន ........ 13

ឧបសម្ព័ន្ធ ........ 15

ឧបសម្ព័ន្ធទី ១ : វេទិកាកសិករថ្នាក់ឃុំ ........ 15

ឧបសម្ព័ន្ធទី ២ : វេទិកាធុរកិច្ចកសិកម្ម នៅថ្នាក់ខេត្ត ........ 16

ឧបសម្ព័ន្ធទី៣: សកម្មភាព និងតម្រូវការប៉ាន់ស្មាន ថវិកា សម្ភារៈសម្រាប់ សកម្មភាពការរៀនសូត្រពីកសិករទៅកសិករ ........ 18

ឧបសម្ព័ន្ធទី៤: ទម្រង់វាយតម្លៃកសិករឆ្នើម ក្លាយជាកសិករគ្រូ ក្នុងសកម្មភាពការរៀនសូត្រពីកសិករទៅកសិករ 20

ឯកសារយោង ........ 22

## ពាក្យបច្ចេកទេសគន្លឹះ

- **ធុរកិច្ចកសិកម្ម (អាជីវកម្មកសិកម្ម)** គឺសំដៅលើការផលិត កសិផលសម្រាប់លក់ដូរ ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ដើម្បីផលចំណេញ។ សូចនាករសំខាន់គឺ ផលិតភាពដី ផលិតភាពពលកម្មគ្រួសារ ផលិតភាពរូបិយប័ណ្ណ វិមាត្រសេដ្ឋកិច្ចនៃផលិតកម្ម។ល។
- **បណ្តុំអាជីវកម្ម** រួមមានអ្នកផលិត អ្នកទិញ និងអ្នកលក់ធាតុចូលដែលមានបំណងធ្វើអាជីវកម្មជាមួយគ្នាលើផលិតកម្មកសិកម្មណាមួយ
- **វេទិកាពហុពាក់ព័ន្ធ** (MSP) ជាការប្រជុំរវាងអ្នកផលិត អ្នកទិញ និងអ្នកលក់ធាតុចូល ដើម្បីពិភាក្សាអំពីផែនការអាជីវកម្មមួយជាក់លាក់ណាមួយដែលលើកឡើងដោយភាគីអ្នកទិញ ឬអ្នកលក់ធាតុចូល។ ដូច្នេះមុននឹងរៀបចំវេទិកាពហុពាក់ព័ន្ធនេះ អ្នកសម្របសម្រួលត្រូវចំណាយពេលពិភាក្សាជាមួយភាគីអ្នកទិញ ឬអ្នកលក់ធាតុចូលឲ្យបានច្បាស់ អំពីផែនការអាជីវកម្មដែលត្រូវធ្វើជាមួយក្រុមកសិករជាមុនសិន
- **សកម្មភាពបន្តពីវេទិកាពហុពាក់ព័ន្ធ** ជាសកម្មភាពសម្រួលឲ្យមានជំនួបរវាងអ្នកផលិត អ្នកទិញ ឬអ្នកលក់ធាតុចូល បន្ទាប់ពីវេទិកាពហុពាក់ព័ន្ធ (MSP) ដើម្បីពិភាក្សាលើបញ្ហាលម្អិត ក្នុងគោលបំណងសម្រេចឲ្យបានកិច្ចព្រមព្រៀងអាជីវកម្មរបស់ពួកគេ។ ជំនួបនេះក៏ជាវេទិកាស្វែងរកតម្រូវការដែលទាមទារឲ្យមានការគាំទ្រពីកម្មវិធីASPIRE ផងដែរ។

## ១. សេចក្តីផ្តើម

គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាបង្ហាញថា សេវាផ្សព្វផ្សាយកសិកម្មអាចផ្តល់ដោយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ទីប្រឹក្សាកសិកម្ម សាកលវិទ្យាល័យ មជ្ឈមណ្ឌលបណ្តុះបណ្តាល វិទ្យាស្ថានស្រាវជ្រាវ ក្រុមកសិករ សហគមន៍កសិកម្មឬអង្គការកសិករ ស្ថាប័នសាសនា និងវត្តអារាម/ព្រះសង្ឃ ដោយសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រាជធានី ខេត្ត។ យន្តការទាំងនេះ ជាការគាំទ្រ សម្របសម្រួល និងផ្សារភ្ជាប់ទំនាក់ទំនងរវាងគ្រប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការអ្នកផលិត និងតម្រូវការទីផ្សារ។

បទពិសោធន៍ នៅក្នុងប្រទេស ជាច្រើនបង្ហាញថាកម្មវិធី ឬគម្រោងទទួលបានជោគជ័យ នៅពេលដែលមានការជួយគាំទ្រ ការផ្សព្វផ្សាយវិស័យកសិកម្ម ទាំងលក្ខណៈផ្លូវការ និងលក្ខណៈក្រៅផ្លូវការ តាមរយៈការផ្តួចផ្តើមការបញ្ជ្រាបចំណេះដឹងពីកសិករទៅកសិករ ។ សកម្មភាពការរៀនសូត្រពីកសិករទៅកសិករ គឺគាំទ្រសមាសភាគទី៣ នៃកម្មវិធី ASPIRE ដើម្បីលើកទឹកចិត្តកសិករនៅក្នុងមូលដ្ឋាន ចែករំលែកជំនាញ និងចំណេះដឹង រវាងកសិករ អ្នកផ្គត់ផ្គង់សម្ភារៈកសិកម្ម និងអ្នកទិញផលិតផល ក៏ដូចជាការចែករំលែកចំណេះដឹង បទពិសោធន៍រវាងកសិករដែលទទួលជោគជ័យលើធុរកិច្ចកសិកម្ម និងកសិករដ៏ទៃទៀត។ ដើម្បីគាំទ្រសកម្មភាពទាំងអស់នេះទទួលបានជោគជ័យ ភ្នាក់ងារផ្សព្វផ្សាយមានតួនាទីបង្ហាញនូវគំនិត និងបច្ចេកទេសកសិកម្មថ្មីៗ ទៅដល់ក្រុមកសិករដែលមិនទាន់ទទួលបានជោគជ័យលើការអនុវត្តធុរកិច្ចកសិកម្ម។ ភ្នាក់ងារផ្សព្វផ្សាយ នឹងទទួលការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍដំណើរការរៀនសូត្រពីកសិករទៅកសិករ ដែលនាំឲ្យមានការអនុវត្តបច្ចេកទេសថ្មីដែលមានប្រសិទ្ធភាព និងទំនើបនៅក្នុងកសិដ្ឋាន។ មិនតែប៉ុណ្ណោះ ភ្នាក់ងារផ្សព្វផ្សាយ អាចទទួលបានព័ត៌មានពី គេហទំព័របណ្តុំព័ត៌មានឯកសារផ្សព្វផ្សាយកសិកម្ម (Extension Web Portal) និងប្រភពព័ត៌មានបច្ចេកទេសផ្សេងៗទៀតតាមបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT)សម្រាប់ធ្វើការបណ្តុះបណ្តាលនិងផ្សព្វផ្សាយដល់កសិករ។ សកម្មភាពទាំងអស់នេះបានចូលរួមយ៉ាងសកម្មនៅក្នុងការជម្រុញឲ្យមានកំណើននៃការអនុវត្តន៍ផលិតកម្មកសិកម្ម ជម្រុញឲ្យមានស្ថិរភាពសេដ្ឋកិច្ចគ្រួសារកសិករល្អប្រសើរ សម្រួលដល់កសិករក្នុងការសម្របខ្លួនតាមស្ថានភាពវិវត្តនៃសាកលភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម បន្សាំនិងការប្រែប្រួលអាកាសធាតុ រួមចំណែកក្នុងការផ្គត់ផ្គង់ផលិតផលកសិកម្មនៅលើទីផ្សារប្រកបដោយប្រសិទ្ធភាព។ ការរៀបចំឲ្យមានការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅទីផ្សារនឹងផ្តល់ឱកាសឲ្យកសិករ សហគមន៍កសិករ រៀនសូត្រ និងធ្វើការជាមួយគ្នា ដែលជាវិធីសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

## ២. គោលបំណង

១. ដើម្បីណែនាំដល់ភ្នាក់ងារផ្សព្វផ្សាយឃុំ/ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម សម្រាប់គាំទ្រដល់ការបង្កើតការរៀនសូត្រពីកសិករទៅកសិករ ។

២. ជាឯកសារគំរូសម្រាប់កម្មវិធី ឬគម្រោងប្រើប្រាស់ក្នុងការអនុវត្តដំណើរការរៀនសូត្រពីកសិករទៅកសិករ។

## ៣. លទ្ធផលរំពឹងទុក

១. ភ្នាក់ងារផ្សព្វផ្សាយឃុំ/ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម មានទំនុកចិត្តក្នុងការអនុវត្ត និងបង្រៀនដល់កសិករក្នុងដំណើរការរៀនសូត្រពីកសិករទៅកសិករ។

២. គោលការណ៍ណែនាំបានប្រើប្រាស់ជាផ្លូវការសម្រាប់កម្មវិធី ឬគម្រោង និងសម្រាប់ប្រើប្រាស់នៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៤. គោលការណ៍គ្រឹះ នៃការរៀនសូត្រពីកសិករទៅកសិករ

១. ចែករំលែកជំនាញ ចំណេះដឹង និងបទពិសោធន៍ ដោយកសិករ ពីការអនុវត្តធុរកិច្ចកសិកម្ម។
២. ផ្តួចផ្តើមគំនិតច្នៃប្រឌិតថ្មីៗដោយកសិករដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។
៣. ការកសាងសមត្ថភាពកសិករ ក្នុងការផ្សព្វផ្សាយបន្ត ប្រកបដោយនិរន្តរភាព។
៤. តម្រង់ទិសការផលិតផលិតផលកសិកម្ម របស់កសិករទៅទីផ្សារ។
៥. បង្កិតសេវាផ្សព្វផ្សាយកសិកម្មទៅដល់មូលដ្ឋាន។

## ៥. ការណែនាំ និងនិតិវិធី ស្តីពីការរៀនសូត្រពីកសិករទៅកសិករ

ការរៀនសូត្រពីកសិករទៅកសិករត្រូវបានទទួលស្គាល់ថាជាវិធីសាស្ត្រនៃការផ្សព្វផ្សាយកសិកម្ម ដែលមានប្រសិទ្ធភាព ក្នុងការជួយផ្តល់សិទ្ធអំណាចដល់កសិករ ក្នុងគោលបំណងបង្ហាញនូវបច្ចេកទេសកសិកម្ម និងការធ្វើអាជីវកម្មកសិកម្ម ដើម្បីបង្កើនប្រាក់ចំណូល និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ជាអ្នកទទួលខុសត្រូវក្នុងការសម្របសម្រួល ការរៀនសូត្រពីកសិករទៅកសិករ។ តួនាទី និងភារៈកិច្ចរបស់ភ្នាក់ងារផ្សព្វផ្សាយឃុំ/ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម គឺការគ្រប់គ្រងក្រុម ការភ្ជាប់ពីក្រុមទៅសកម្មភាពផ្សេងៗរបស់កម្មវិធី ឬគម្រោង និងគាំទ្របច្ចេកទេសផ្សេងៗដែលកសិករត្រូវការ។ បន្ទាប់មកទៀត ការគាំទ្រពីភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដល់ក្រុមការរៀនសូត្រពីកសិករទៅកសិករនឹងត្រូវកាត់បន្ថយ។ ក្នុងគោលបំណងឲ្យក្រុមកសិកររៀនសូត្រពីកសិករទៅកសិករដើម្បីបង្កើននូវភាពឯករាជ្យខ្លួនឯង តាមរយៈការពង្រឹងភាពជាអ្នកដឹកនាំក្រុម និងសមត្ថភាពគ្រប់គ្រង។

សមាជិកក្រុមរៀនសូត្រពីកសិករទៅកសិករ ក៏ត្រូវស្វែងរកព័ត៌មាន ដោយប្រើវិធីសាស្ត្រជាច្រើន ដូចជាការទទួលយកព័ត៌មានតាមប្រព័ន្ធ បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ (គេហទំព័របណ្តុំព័ត៌មានឯកសារផ្សព្វផ្សាយកសិកម្ម-Extension Portal) និងការបង្កើតនូវបណ្តាញប្រភពធនធានព័ត៌មានយ៉ាងទូលំទូលាយ។ ការទទួលបានព័ត៌មាននិងជួយឲ្យកសិករអាចប្រើប្រាស់ និងសម្រេចលទ្ធផលនៃការសិក្សាបានល្អប្រសើរ។ ការភ្ជាប់ជាមួយអ្នកផ្តល់ព័ត៌មានផ្សេងៗទៀត អ្នកជំនាញបច្ចេកទេសពីអង្គភាពដែលធ្វើការស្រាវជ្រាវ ផ្សព្វផ្សាយ និងអ្នកផ្តល់សេវាឯកជននឹងជួយឲ្យសមាជិកក្រុមកសិករទទួលយកនូវព័ត៌មានយ៉ាងទូលំទូលាយលើសពីនេះទៀត ការចូលរួមរបស់កសិករក្នុងសកម្មភាពដូចជា៖ វេទិកាកសិករ ការតាំងពិព័រណ៌ សិក្ខាសាលាផ្សព្វផ្សាយកសិកម្ម ទស្សនៈកិច្ច ។ល។ ដែលអាចផ្តល់នូវបទពិសោធន៍ និងចំណេះដឹងដែលអាចចែករំលែករវាងកសិករ និងកសិករ។

## ៦. ចរិតលក្ខណៈ នៃការរៀនសូត្រពីកសិករទៅកសិករ

ជាទូទៅកសិករទទួលយកការណែនាំ ការផ្តល់ដំបូន្មាន ការទទួលព័ត៌មានពីកសិករផ្សេងៗ ។ ការអនុវត្តផ្ទាល់នៅក្នុងកសិដ្ឋានជួយឲ្យកសិករអាចរៀនសូត្រនិងទទួលបានបទពិសោធន៍ជាក់ស្តែងនៅក្នុងកសិដ្ឋាន និងទទួលបានប្រាក់ចំណូលខ្ពស់។ សកម្មភាពការសិក្សាពីកសិករទៅកសិករ គឺបង្ហាញ និងជំរុញ ដោយក្រុមកសិករខ្លួនឯង ដោយផ្តោតលើតម្រូវការរបស់កសិករ។

ផ្តល់ឱកាសដើម្បីកសាងជំនាញ និងសមត្ថភាពរបស់កសិករ ក្នុងសហគមន៍មូលដ្ឋានឲ្យចេះចាត់ចែងរៀបចំ និងការកសាងសមត្ថភាព ជំនាញភាពជាអ្នកដឹកនាំនៅមូលដ្ឋានក្នុងសហគមន៍ ដោយរាប់បញ្ចូលទាំងការទំនាក់ទំនងប្រវាក់ទីផ្សារ ការអភិវឌ្ឍទីផ្សារ ការធ្វើបង្ហាញ ការគ្រប់គ្រងកសិដ្ឋាន ដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យ។ ក្រុមកសិករជាអ្នកកំណត់តម្រូវការជាក់លាក់ ដោយធ្វើការវិភាគតម្រូវការ មានការសម្របសម្រួល

ពីភ្នាក់ងារផ្សព្វផ្សាយឃុំ/ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដើម្បីធានាថាសកម្មភាពការសិក្សាពីកសិករទៅកសិករ ត្រូវតាមតម្រូវការអ្នកប្រើប្រាស់។

## ៧. ជំហាននៃការអនុវត្តន៍

ដើម្បីសម្រេចបាននូវការអនុវត្តទៅលើគោលការណ៍ណែនាំឲ្យបានច្បាស់លាស់ តម្រូវឲ្យភ្នាក់ងារផ្សព្វផ្សាយអនុវត្ត ទៅតាមជំហានដូចខាងក្រោម៖

១. ជ្រើសរើសកសិករគំរូ

២. បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពកសិករគំរូ

៣. ជ្រើសរើសកសិករឆ្នើម (Outstanding Farmer/Elite/Champion Farmer)

៤. បណ្តុះបណ្តាលកសិករឆ្នើម ក្លាយជាកសិករគ្រូ (TOT) ១នាក់/ភូមិ ឬ ១នាក់/ឃុំ

៥. ការបង្កើតបណ្តាញកសិករ។

**<u>ជំហាននៃការអនុវត្តន៍</u>**




### ៧.១. ជ្រើសរើសកសិករគំរូ (Demo Farmer)

ការជ្រើសរើសកសិករគំរូគួរធ្វើការជ្រើសរើសចេញពីការកសិករក្រុមគោលដៅ ឬកសិករដែលមានសក្តានុពលដែលធ្វើបង្ហាញឬកសិករអនុវត្តក្នុងភូមិបានជោគជ័យ។

#### ៧.១.១. គោលបំណង

ដើម្បីបង្ហាញនូវបច្ចេកវិទ្យាថ្មីៗធន់ទៅនឹងអាកាសធាតុប្រែប្រួល ឆ្លើយតបតម្រូវការទីផ្សារ និងការអនុវត្តក្នុងកសិដ្ឋានបានជោគជ័យ ទៅដល់សមាជិកផ្សេងៗនិងកសិករក្នុងភូមិ។

#### ៧.១.២. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករគំរូ

- ស្ម័គ្រចិត្ត មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមជាមួយកម្មវិធីឬគម្រោង ដោយគ្មានការបង្ខិតបង្ខំ
- អនុវត្តនៅកសិដ្ឋានបានជោគជ័យលក្ខណៈជាអាជីព
- មានអាយុយ៉ាងហោចណាស់ ចាប់ពី១៨ឆ្នាំ ដល់ ៥៥ឆ្នាំ
- ចេះអាន និងសរសេរអក្សរខ្មែរបានខ្លះ
- អនុវត្តបច្ចេកទេស តាមការណែនាំរបស់កម្មវិធី ឬគម្រោងដូចដែលបានឯកភាពក្នុងកិច្ចព្រមព្រៀង
- មានទីលំនៅពិតប្រាកដ
- មានធនធាន និងពេលវេលាគ្រប់គ្រាន់ចូលរួម
- មានទំនាក់ទំនងល្អជាមួយសមាជិកក្នុងក្រុម និងកសិករក្នុងភូមិ
- ចែករំលែកចំណេះដឹងថ្មីដែលបានអនុវត្តក្នុងកសិដ្ឋានទៅដល់សមាជិកផ្សេងៗ
- ជាស្ត្រី/បុរសពិការ ប៉ុន្តែមានលទ្ធភាពក្នុងការអនុវត្តសកម្មភាពការធ្វើបង្ហាញ

- ជាស្ត្រីមេគ្រួសារឧស្សាហរណ៍ព្យាយាម
- អនុវត្តតាមយន្តការចែករំលែកសមិទ្ធផល នៃការធ្វើបង្ហាញដល់សមាជិកក្រុមបន្ត
- មានកសិដ្ឋានដាំដុះសមស្របតាមលក្ខណៈបច្ចេកទេស។

### ៧.១.៣. ដំណើរការជ្រើសរើសកសិករគំរូ

៧.១.៣.១. ប្រជុំផ្សព្វផ្សាយដើម្បីជ្រើសរើសកសិករគំរូ (បង្ហាញគោលបំណង លក្ខណៈវិនិច្ឆ័យ តួនាទី និងការទទួលខុសត្រូវ )

៧.១.៣.២. ចុះពិនិត្យជាក់ស្តែងតាមកសិដ្ឋាន ដោយមន្ត្រីបច្ចេកទេសមន្ទីរកសិកម្ម ខេត្ត/ស្រុក និងដៃគូអភិវឌ្ឍន៍នានា

៧.១.៣.៣. ការជ្រើសរើស (បោះឆ្នោត ឬលើកដៃ): ជ្រើសរើស ១ ទៅ ២នាក់/ភូមិ (ស្ត្រីត្រូវបានលើកទឹកចិត្ត)។

## ៧.២. បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពកសិករគំរូ

### ៧.២.១. គោលបំណង

ពង្រឹងសមត្ថភាពបន្ថែមដល់កសិករគំរូ ដែលបានជ្រើសរើសស្របតាមតម្រូវការរបស់គាត់ ដើម្បីឲ្យគាត់មានជំនាញគ្រប់គ្រាន់ក្នុងការអនុវត្តជាក់ស្តែងនៅក្នុងកសិដ្ឋាន ឆ្លើយតបទៅនិងតម្រូវការទីផ្សារ និងចែករំលែកបទពិសោធន៍ដល់កសិករដទៃទៀត។

### ៧.២.២. ដំណើរការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលនៅមូលដ្ឋាននិងអនុវត្តផ្ទាល់ ដោយមន្ត្រីបច្ចេកទេសកសិកម្ម
- សិក្សាតម្រូវការបណ្តុះបណ្តាលរបស់កសិករ និងកំណត់ប្រធានបទ
- រៀបចំផែនការបណ្តុះបណ្តាល និង កំណត់ពេលវេលាជាមួយកសិករ
- រៀបចំសម្ភារៈបណ្តាល និងអនុវត្តការបណ្តុះបណ្តាល
- វាយតម្លៃចំណេះដឹងនៃការបណ្តុះបណ្តាល (មុននិងក្រោយវគ្គ)
- រៀបចំផែនការអភិវឌ្ឍន៍កសិដ្ឋានរបស់កសិករ (គូសផែនទី និងប្លង់ដាំដុះក្នុងកសិដ្ឋាន)។

### ៧.២.៣. តាមដាន និងវាយតម្លៃការអនុវត្តជាក់ស្តែងនៅក្នុងកសិដ្ឋានរបស់កសិករ

- ការតាមដាននេះបន្ទាប់ពីកសិករបានចូលរួមវគ្គបណ្តុះបណ្តាល និងអនុវត្តន៍នៅក្នុងកសិដ្ឋាន
- យ៉ាងយូរក្នុងរយៈពេល៣ខែ ក្រោយពេលបណ្តុះបណ្តាល
- ប្រជុំឆ្លុះបញ្ចាំង និងវាយតម្លៃដោយមន្ត្រីបច្ចេកទេសពាក់ព័ន្ធ
    - មន្ត្រីបច្ចេកទេសថ្នាក់ខេត្ត ១នាក់
    - ប្រធាន/មន្ត្រីការិយាល័យកសិកម្មស្រុក ១នាក់
    - អាជ្ញាធរដែនដី ភូមិ/ឃុំ ២នាក់។

## ៧.៣. ការជ្រើសរើសកសិករឆ្នើម (Elite/Outstanding Farmers/Champion Farmer) ១នាក់/ឃុំ ឬ ១នាក់/ភូមិ

### ៧.៣.១. គោលបំណង:

ជ្រើសរើសកសិករដែលមានស្នាដៃឆ្នើមក្នុងចំណោមកសិករគំរូ ដើម្បីចែករំលែកបទពិសោធន៍និងភាពជោគជ័យនៃការអនុវត្តនៅលើកសិដ្ឋាន ទៅដល់កសិករដទៃ និងយកទៅបណ្តុះបណ្តាលដើម្បីក្លាយជាកសិករគ្រូ។

### ៧.៣.២. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករឆ្នើម

- ជាកសិករដែលជោគជ័យក្នុងការអនុវត្តធុរកិច្ចកសិកម្ម
- មានធនធាន និងពេលវេលាគ្រប់គ្រាន់ចូលរួមសកម្មភាពកម្មវិធី

- មានទំនាក់ទំនងល្អជាមួយសមាជិកក្នុងក្រុម និងកសិករក្នុងភូមិ
- ចែករំលែកចំណេះដឹងថ្មីដែលទទួលបានជោគជ័យក្នុងការអនុវត្តធុរកិច្ចកសិកម្មទៅដល់សមាជិកផ្សេងៗ
- ជាមានគំនិតច្នៃប្រឌិតច្រើនជាងកសិករគំរូ
- មានគំនិតចែករំលែក និងសកម្មការងារនៅក្នុងកសិដ្ឋានច្រើនជាងគេ
- អនុវត្តតាមការសន្យាដែលបានឯកភាព
- មានជំនាញទំនាក់ទំនង ការប្រាស្រ័យទាក់ទង ជំនាញសម្របសម្រួល និងការគ្រប់គ្រងក្រុម ដឹកនាំសហគមន៍។

**៧.៣.៣. ដំណើរការជ្រើសរើសកសិករឆ្នើម**

- ការបង្កើតគណៈកម្មាការជ្រើសរើស និងវាយតម្លៃ (មន្ត្រីបច្ចេកទេសថ្នាក់ខេត្ត ១នាក់ ថ្នាក់ស្រុក ១នាក់ និងអាជ្ញាធរដែនដី ភូមិ/ឃុំ ២នាក់)
- ផ្សព្វផ្សាយ និងជ្រើសរើសកសិករដែលចាប់អារម្មណ៍
- តាមដាន និងវាយតម្លៃលើការអនុវត្តនៅក្នុងកសិដ្ឋាន ដែលទទួលបានជោគជ័យក្នុងការអនុវត្តធុរកិច្ចកសិកម្ម
- ប្រជុំឆ្លុះបញ្ចាំង និងវាយតម្លៃដោយមន្ត្រីបច្ចេកទេសពាក់ព័ន្ធ
    - មន្ត្រីបច្ចេកទេសថ្នាក់ខេត្ត ១នាក់
    - ប្រធាន/មន្ត្រីការិយាល័យកសិកម្មស្រុក ១នាក់
    - អាជ្ញាធរដែនដី ភូមិ/ឃុំ ២នាក់។

## ៧.៤. បណ្តុះបណ្តាលកសិករឆ្នើម ក្លាយជាកសិករគ្រូ (TOT Champion farmer to became a Farmer Trainer)

ផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោល លើប្រធានបទជាមូលដ្ឋានៈ

- វិធីសាស្ត្របង្រៀន (កិច្ចតែងការបង្រៀន)
- វិធីសាស្ត្រផ្សព្វផ្សាយកសិកម្មៈ
    - តួនាទី និងផែនការជាក់លាក់ របស់អ្នកផ្សព្វផ្សាយ ក្នុងការអភិវឌ្ឍន៍និងការរកឃើញនូវអ្វីៗដែលថ្មី
    - ការគ្រប់គ្រងកម្មវិធីផ្សព្វផ្សាយកសិកម្ម (១) តម្រូវការកសិករ (២) ការអនុវត្ត (៣) ការតាមដាន និងវាយតម្លៃ
    - ជំនាញទំនាក់ទំនង និងការសម្របសម្រួល (សម្រាប់ការសិក្សារបស់មនុស្សវ័យ)
- ការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅកាន់ទីផ្សារ (បណ្តុំអាជីវកម្មកសិកម្ម -Business Cluster)
- យេនឌ័រ និងយុវជន ក្នុងការផ្សព្វផ្សាយកសិកម្ម និងសេវាប្រឹក្សាយោបល់
- សហគ្រិនអាជីវកម្មកសិកម្ម (Agriculture Entrepreneurship)
- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងវិធីសាស្ត្របន្សាំក្នុងវិស័យកសិកម្ម
- ការអនុវត្តប្រព័ន្ធនវានុវត្តន៍កសិកម្មថ្មីៗ
- បណ្តុះបណ្តាលពី ការអនុវត្តកសិកម្មល្អ (GAP)
- ប្រព័ន្ធទំនាក់ទំនងសង្គម (Social Media)
- ការថត Videoខ្លីៗ នៅក្នុង SMART Phone រយៈពេលខ្លី ប្រហែល ១នាទី ដើម្បីចែករំលែក ពីការទទួលយក និងការអនុវត្តន៍នូវបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗទៅក្នុង Facebook ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ
- ទស្សនៈកិច្ចសិក្សា
- បណ្តុះបណ្តាលបន្ថែមឆ្លើយតបតាមតម្រូវការ ឬការចាំបាច់ផ្សេងៗស្របតាមស្ថានភាពមូលដ្ឋានជាក់ស្តែង។

## ៧.៥. ការបង្កើតបណ្តាញកសិករ

គឺជាការចែករំលែក បទពិសោធន៍ និងភាពជោគជ័យលើការអនុវត្តធុរកិច្ចកសិកម្មរបស់កសិករឆ្នើម/កសិករគ្រូ ទៅដល់ក្រុមកសិករផ្សេងទៀតដែលកំពុងអនុវត្តធុរកិច្ចកសិកម្ម។ ដើម្បីបង្កើតបណ្តាញទទួលបានជោគជ័យត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

១. ទស្សនៈកិច្ចសិក្សាកសិករជោគជ័យ លើការអនុវត្តធុរកិច្ចកសិកម្ម

២. កសិករឆ្នើម/កសិករគ្រូបណ្តុះបណ្តាលក្រុមកសិករ ដែលកំពុងអនុវត្តធុរកិច្ចកសិកម្ម (មិនទាន់ជោគជ័យក្នុងធុរកិច្ចកសិកម្ម)

៣. រៀបចំវេទិការៀនសូត្ររវាង កសិករ អ្នកបច្ចេកទេស វិស័យឯកជន និងអ្នកពាក់ព័ន្ធ។

**<u>ជំហាននៃការអនុវត្តន៍</u>**




## ១.ទស្សនៈកិច្ចសិក្សាកសិករជោគជ័យលើការអនុវត្តធុរកិច្ចកសិកម្ម

បន្ទាប់ពីទទួលបានតម្រូវការដែលបានលើកឡើងក្នុងវេទិកាពហុភាគីពាក់ព័ន្ធ(MSP) ឬការប្រជុំបណ្តុំអាជីវកម្មភ្នាក់ងារផ្សព្វផ្សាយឃុំ ដឹកនាំក្រុមកសិករទៅទស្សនៈកិច្ចសិក្សាកសិករដែលជោគជ័យ លើការអនុវត្តធុរកិច្ចកសិកម្ម។

### ១.១.គោលបំណង

ផ្តល់ឱកាសឲ្យកសិករជាសមាជិកបណ្តុំអាជីវកម្មកសិកម្ម បានសិក្សាស្វែងយល់បន្ថែមពីការអនុវត្ត នូវបទពិសោធន៍ បច្ចេកទេសកសិកម្មថ្មីៗ និងភាពទទួលជោគជ័យ នៃការអនុវត្តធុរកិច្ចកសិកម្ម ពីកសិករឆ្នើម/កសិករគ្រូ តាមប្រធានបទដែលខ្លួនចាប់អារម្មណ៍។

### ១.២. លទ្ធផលរំពឹងទុក

ក្រុមកសិករទទួលបាន នូវបទពិសោធន៍ បច្ចេកទេសល្អៗ និងភាពជោគជ័យនៃការអនុវត្តធុរកិច្ចកសិកម្ម ពីកសិករឆ្នើម/កសិករគ្រូ ដើម្បីយកទៅអនុវត្តក្នុងកសិដ្ឋានរបស់ពួកគេត្រូវតាមតម្រូវការទីផ្សារ និងទទួលបាននូវប្រាក់ចំណូលខ្ពស់។

### ១.៣.ការរៀបចំទស្សនៈកិច្ចសិក្សា

- កំណត់ប្រធានបទនៃទស្សនៈកិច្ចសិក្សា ដោយផ្អែកលើតម្រូវការកសិករ
- ជ្រើសរើសទីកន្លែងសម្រាប់ធ្វើធ្វើទស្សនៈកិច្ចសិក្សា ដូចជាផ្ទះកសិករឆ្នើម/កសិករគ្រូ កសិដ្ឋានដែលធ្វើអាជីវកម្មកសិកម្មទទួលបានជោគជ័យ ហើយក្រុមកសិករអាចយកបច្ចេកទេសទៅអនុវត្តបន្តបានត្រូវតាមតម្រូវការទីផ្សារ
- កំណត់ចំនួនកសិករដែលជាសមាជិកបណ្តុំអាជីវកម្មកសិកម្ម ដើម្បីចូលរួមទស្សនៈកិច្ចសិក្សា (១៥-២០នាក់)។

## ២.កសិករឆ្នើម/កសិករគ្រូបណ្តុះបណ្តាលដល់ក្រុមកសិករ

ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ត្រូវធ្វើការជាមួយនឹងកសិករឆ្នើម/កសិករគ្រូ ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាល ឯកសារមេរៀន និងសម្ភារៈផ្សេងៗទៀតដើម្បីបណ្តុះបណ្តាលដល់ក្រុមកសិករ ដែលអនុវត្តធុរកិច្ចកសិកម្មមិនទាន់បានជោគជ័យ ឬកសិករដែលទើបចាប់ផ្តើមអនុវត្ត។

### ២.១.គោលបំណង

- បង្ហាញពីវិធីសាស្ត្រក្នុងការអនុវត្តកសិកម្មល្អ (GAP)
- បង្ហាញពីបទពិសោធន៍ នៃការអនុវត្តបច្ចេកទេសកសិកម្មថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- ការធ្វើផែនការដាំដុះ និងផលិត
- ការរៀបចំផែនការលក់ និងវិធីសាស្ត្រផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកលក់ធាតុចូលកសិកម្ម អ្នកទិញ សហគមន៍កសិកម្ម ឬអង្គការកសិករ ក្នុងការលក់ផលិតផល ដោយអនុវត្តកសិកម្មតាមកិច្ចសន្យា។

### ២.២. លទ្ធផលរំពឹងទុក

- កសិករអាចយល់ដឹងពីពេលវេលាក្នុងការដាំដុះ ដើម្បីកាត់បន្ថយនូវហានិភ័យផ្សេងៗ ដែលកើតឡើងដោយសារការប្រែប្រួលអាកាសធាតុ ឬគ្រោះមហន្តរាយធម្មជាតិ
- យល់ដឹងអំពី កត្តាប្រឈមផ្សេងៗដែលកើតឡើងកំឡុងពេលអនុវត្តធុរកិច្ចកសិកម្ម (សត្វល្អិត គ្រោះមហន្តរាយ តម្លៃទីផ្សារផលិតផល និងតម្លៃធាតុចូលកសិកម្ម)
- ក្រុមកសិករចេះធ្វើផែនការអាជីវកម្មត្រូវតាមតម្រូវការទីផ្សារ និងការកត់ត្រាចំណូល-ចំណាយ
- ក្រុមកសិករបានស្វែងយល់ពីសារៈសំខាន់ក្នុងការធ្វើទំនាក់ទំនងជាមួយ និងអ្នកផ្គត់ផ្គង់ធាតុចូល និងឈ្មួញអ្នកទិញផលិផល
- យល់ដឹងពីវិធីសាស្ត្របង្កើនគុណភាពផលិតផលទៅទីផ្សារ តាមរយៈការធ្វើចំណាត់ថ្នាក់លាងសម្អាត និងការវេចខ្ចប់ ដឹកជញ្ជូនជាដើម។

### ២.៣. សកម្មភាព

កសិករឆ្នើម/កសិករគ្រូត្រូវរៀបចំសកម្មភាពមួយចំនួនដូចជា៖

- រៀបចំឯកសារ សម្ភារៈ និងចងក្រងនូវបទពិសោធន៍ល្អៗសម្រាប់បង្ហាញដល់សិក្ខាកាម
- នាំសិក្ខាកាមចុះពិនិត្យ និងអនុវត្តផ្ទាល់នៅក្នុងកសិដ្ឋាន ដូចជា៖ ការដាំដុះ ការងារធ្វើផែនការផលិត ការងារទំនាក់ទំនងជាមួយឈ្មួញអ្នកទិញផលិតផលជាដើម
- កសិករឆ្នើម/កសិករគ្រូចុះពិនិត្យសកម្មភាពធ្វើអាជីវកម្មកសិកម្មរបស់ក្រុមកសិករនិងការណែនាំបន្ថែម និងការកត់ត្រាចំណូល-ចំណាយក្នុងការផលិត។

## ៣. រៀបចំវេទិការៀនសូត្ររវាងកសិករ អ្នកបច្ចេកទេស វិស័យឯកជន និងអ្នកពាក់ព័ន្ធ

វេទិកានេះរៀបចំឡើង ក្នុងគោលបំណងដើម្បី ចែករំលែកការអនុវត្តបច្ចេកទេសកសិកម្មថ្មីៗដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ បទពិសោធន៍ការអនុវត្តធុរកិច្ចកសិកម្ម និងបង្កើនទំនាក់ទំនងរវាងអ្នកបច្ចេកទេស អ្នកលក់ធាតុចូល ឈ្មួញអ្នកទិញ។ វេទិកានេះត្រូវរៀបចំឡើងនៅកម្រិតថ្នាក់ឃុំ និងថ្នាក់ខេត្ត។

### ៣.១.វេទិកាកសិករថ្នាក់ឃុំ

វេទិកាថ្នាក់ឃុំ គឺរៀបចំឡើងដោយមានការចូលរួមពី ភ្នាក់ងារផ្សព្វផ្សាយ វិស័យឯកជន អ្នកផ្គត់ផ្គង់ធាតុចូល អ្នកផលិត/សមាជិកបណ្តុំអាជីវកម្ម និងកសិករឆ្នើម/កសិករគ្រូ។

### ៣.២.១. គោលបំណង

- ផ្តល់ឱកាសឲ្យកសិករ និងអ្នកពាក់ព័ន្ធផ្សេងៗ ចែករំលែក បទពិសោធន៍ ចំណេះដឹង និងដោះស្រាយបញ្ហាពី ទីផ្សារ ការអនុវត្តអាជីវកម្មកសិកម្មដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការរៀបចំផែនការដាំដុះនិងផលិតក្នុងការត្រៀមបង្ការគ្រោះមហន្តរាយផ្សេងៗ ។

### ៣.២.២. លទ្ធផលរំពឹងទុក

- កសិករបានពិភាក្សា ចែករំលែកបទពិសោធន៍ ដោះស្រាយបញ្ហា ដែលបានជួបប្រទះក្នុងការអនុវត្តផលិតកម្មកសិកម្ម និងដើម្បីលើកកម្ពស់ផលិតភាព គុណភាព សុវត្ថិភាពផលិតផលកសិកម្ម ទីផ្សារកសិផល ព្រមទាំងបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងបង្កើនប្រាក់ចំណូលគ្រួសារ។
- កសិករបានបង្កើនទំនាក់ទំនងរវាងកសិករ អ្នកបច្ចេកទេស អ្នកផ្គត់ផ្គង់សម្ភារៈកសិកម្ម និងឈ្មួញអ្នកទិញផលិតផល។

## ៣.៣. វេទិកាធុរកិច្ចកសិកម្ម នៅថ្នាក់ខេត្ត

វេទិកាថ្នាក់ខេត្ត រៀបចំឡើងដោយមានការចូលរួមពី មន្ទីរកសិកម្ម វិស័យឯកជន អ្នកផ្គត់ផ្គង់ធាតុចូល អ្នកផលិត/សមាជិកបណ្តុំអាជីវកម្ម និងកសិករឆ្នើម/កសិករគ្រូ ស្ថាប័នមីក្រូហិរញ្ញវត្ថុដោយមានការធ្វើបទបង្ហាញពីស្ថាប័នពាក់ព័ន្ធ និងការតាំងពិព័ណ៌សម្ភារៈនឹងផលិតផលកសិកម្មផ្សេងៗ។

### ៣.៣.១.គោលបំណង

- បង្ហាញពីសមិទ្ធផលការអនុវត្តធុរកិច្ចកសិកម្ម របស់បណ្តុំអាជីវកម្មកសិកម្ម
- ដើម្បីចែករំលែកបទពិសោធន៍ និងការអនុវត្តល្អៗក្នុងការទំនាក់ទំនងលក់ផលិតផលទៅកាន់ទីផ្សារ
- បង្ហាញពីបច្ចេកទេសកសិកម្មថ្មីៗដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

### ៣.២.២.លទ្ធផលរំពឹងទុក

- មានឱកាសដើម្បីប្រៀបធៀប នូវដំណោះស្រាយឆ្លៃប្រឌិត និងចែករំលែក នូវការអនុវត្តល្អបំផុត ចំពោះ ច្រវាក់តម្លៃកសិផល នៅក្នុងខេត្ត
- បង្កើតបានភាពជាដៃគូអាជីវកម្ម និងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នកផលិត អ្នកទិញ និងអ្នកផ្គត់ផ្គង់ (ការអនុវត្តកសិកម្មតាមកិច្ចសន្យា)
- មានឱកាសល្អ ដើម្បីរៀនសូត្រ និងបង្កើនចំណេះដឹង អំពីបច្ចេកទេសកសិកម្មថ្មីៗដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

# ៤. សកម្មភាពសិក្សាពីកសិករទៅកសិករ

វិធីសាស្រ្តនៃការរៀនសូត្រពីកសិករទៅកសិករបញ្ចូលរបៀបថ្មីដើម្បីជួយដល់កសិករ ក្នុងការកសាងជំនាញ និងសមត្ថភាពរបស់គេ រួមទាំងវិធីសាស្រ្តសិក្សាតម្រូវការអ្នកប្រើប្រាស់។ ការរៀនសូត្រពីកសិករទៅកសិករ មានសារៈសំខាន់ និងមានអន្តរអំពើទៅវិញទៅមក គឺការចែករំលែក នូវព័ត៌មាន ចំណេះដឹង និងបទពិសោធន៍ គឺត្រូវបានលើកទឹកចិត្ត ។ សកម្មភាពជាច្រើនក្នុងការគាំទ្រសកម្មភាពការរៀនសូត្រពីកសិករទៅកសិករៈ

- ការធ្វើបង្ហាញនៅក្នុងកសិដ្ឋាននិងការប្រៀបធៀបនូវភាពខុសគ្នា រវាងការអនុវត្តតាមបែបប្រពៃណី និងការអនុវត្តនូវបច្ចេកវិទ្យាថ្មីក្នុងកសិដ្ឋាន
- ការបង្កើតឡើងនូវអាជីវកម្មដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (បច្ចេកទេស ការដាំដំណាំ.... ឱកាសអាជីវកម្ម និងហានិភ័យនៃអាជីវកម្ម) និងការកំណត់ ឲ្យបានច្បាស់លាស់នូវការអនុវត្តនៅក្នុងកសិដ្ឋាន ដែលអាចបន្ធូរបន្ថយនូវផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ

- ការចងក្រងបណ្ដុំអាជីវកម្មកសិកម្ម (Business Cluster) និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅកាន់ទីផ្សារ
- ការជួយកំណត់ ឱកាសទីផ្សារក្នុងមូលដ្ឋាន និងការបន្ថែមឱកាសតម្លៃ
- ការតាមដាន ដំណាំ ការចិញ្ចឹមសត្វ.... និងការដើរពិនិត្យដំណាំនៅតាមវាល នេះក៏ជាផ្នែកមួយនៃការអនុវត្តនូវបច្ចេកទេសថ្មីនៅក្នុងកសិដ្ឋាន ដោយផ្ដោតលើបរិបទនៃបរិស្ថានកសិដ្ឋាននៅក្នុងមូលដ្ឋាន
- បង្កើនជំនាញ ភាពជាអ្នកដឹកនាំ ការទំនាក់ទំនង សម្របសម្រួលក្រុម និងក្នុងចំណោមសហគមន៍
- ការសហការណ៍ គាំទ្រសកម្មភាពការបណ្ដុះបណ្ដាល និងការកសាងសមត្ថភាពនៅមូលដ្ឋានទាក់ទងទៅនិងតម្រូវការ បញ្ហា និងឱកាស
- ជួយភ្នាក់ងារផ្សព្វផ្សាយក្នុងការលើកកំពស់ " **ការអនុវត្តការគ្រប់គ្រងល្អ** " ដែលអភិវឌ្ឍន៍សម្រាប់សហគ្រិនអាជីវកម្មកសិកម្ម
- ក្រុមកសិករ សិក្សាពីកសិករទៅកសិករ ទៅទស្សនៈកិច្ចបទពិសោធន៍ការរកឃើញថ្មីៗ ដោយការអនុវត្តផ្ទាល់នៅក្នុងកសិដ្ឋាន របស់កសិករឆ្នើម/កសិករគ្រូ
- វេទិកាកសិករថ្នាក់ឃុំ ១ដង/ឃុំ/ឆ្នាំ
- ការបណ្ដុះបណ្ដាលកសិករគ្រូ តាមការស្នើសុំ
- ការចងក្រងបណ្ដាញ កសិករគ្រូ នៅកម្រិតថ្នាក់ឃុំ
- ការអនុវត្តតួនាទីជាកសិករគ្រូ ក្នុងការតាមដាន ការផ្ដល់យោបល់ដល់ក្រុមកសិករ និងកសិករដែលមានចំណាប់អារម្មណ៍ចូលរួមជាមួយបណ្ដុំអាជីវកម្មកសិកម្ម
- ការរៀបចំវេទិកាធុរកិច្ចកសិកម្មនៅថ្នាក់ខេត្ត ១ដង/ឃុំ/ឆ្នាំ។

## ៩. តួនាទី និងភារកិច្ច

### ❖ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

- រៀបចំគោលការណ៍ណែនាំ និងផ្សព្វផ្សាយស្ដីពីការរៀនសូត្រពីកសិករទៅកសិករដល់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការជាមួយនាយកដ្ឋានជំនាញ រៀបចំឯកសារបច្ចេកទេស និងផ្ដល់វគ្គបណ្ដុះបណ្ដាលដល់គ្រូបង្គោល មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកសិករឆ្នើម/កសិករគ្រូ តាមតម្រូវការ
- ចូលរួមប្រជុំដើម្បីពិនិត្យឡើងវិញ និងធ្វើឲ្យប្រសើរនូវការអនុវត្តន៍គោលការណ៍ ការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅកាន់ទីផ្សារ
- តាមដាន លទ្ធផល និងគុណភាព នៃការអនុវត្តគោលការណ៍ណែនាំពី ការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅកាន់ទីផ្សារ។

### ❖ មន្ត្រីបច្ចេកទេស មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាក់រាជធានី/ខេត្ត

- សម្របសម្រួលការរៀបចំផែនការថវិកា អនុវត្តសកម្មភាព ការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅកាន់ទីផ្សារ
- បណ្ដុះបណ្ដាល ការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅកាន់ទីផ្សារ ដល់មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ/ភ្នាក់ងារផ្សព្វផ្សាយ
- ចូលរួមជ្រើសរើស តាមដាន វាយតម្លៃ កសិករគំរូ កសិករឆ្នើម កសិករគ្រូ
- ជួយរៀបចំបណ្ដាញ និងព័ត៌មានទីផ្សារ
- ស្វែងរកដៃគូអាជីវកម្ម និងវិស័យឯកជន
- ដឹកនាំដំណើរការអនុវត្តន៍គោលការណ៍ ការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅកាន់ទីផ្សារ

- ដឹកនាំ និងចងក្រងបណ្តាញការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅទីផ្សារ
- សម្របសម្រួល និងបណ្តុះបណ្តាលបច្ចេកទេស
- រៀបចំទស្សនៈកិច្ចសិក្សារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការិយាល័យកសិកម្មស្រុក ការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅកាន់ទីផ្សារ ទៅក្រៅប្រទេស
- សហការជាមួយការិយាល័យពាក់ព័ន្ធ
- ផ្តល់ការទទួលស្គាល់ជាកសិករគ្រូ ពីអាជ្ញាធរមូលដ្ឋាន និងពីមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- របាយការណ៍សកម្មភាព ការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅកាន់ទីផ្សារ ជូនក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងចម្លងជូននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងនាយកដ្ឋានផែនការស្ថិតិ។

❖ **មន្ត្រីបច្ចេកទេសការិយាល័យកសិកម្មក្រុង/ស្រុក/ខណ្ឌ**

- ដឹកនាំជ្រើសរើសកសិករ គំរូ កសិករឆ្នើម កសិករគ្រូ
- ដឹកនាំបណ្តុះបណ្តាលពីការអនុវត្តជាក់ស្តែង នៅកសិដ្ឋាន ( Demo training )
- សហការការងារ និងសម្របសម្រួលរាល់ការងារជាមួយមន្ត្រីថ្នាក់ខេត្ត
- ចូលរួមរៀបចំផែនការថវិកា អនុវត្តសកម្មភាព ការរៀនសូត្រពីកសិករទៅកសិករ
- ចូលរួមជ្រើសរើស តាមដាន វាយតម្លៃ កសិករគំរូ កសិករឆ្នើម កសិករគ្រូ
- ចូលរួមជួយរៀបចំបណ្តាញ និងព័ត៌មានទីផ្សារ
- ចូលរួមស្វែងរកដៃគូអាជីវកម្ម និងវិស័យឯកជន
- ដឹកនាំដំណើរការអនុវត្តន៍គោលការណ៍ ការរៀនសូត្រពីកសិករទៅកសិករ
- ចូលរួមសម្របសម្រួលការងារបច្ចេកទេស
- ចូលរួមសហការជាមួយការិយាល័យពាក់ព័ន្ធ
- សម្របសម្រួលដើម្បីទទួលស្គាល់ជាកសិករគ្រូ និងពីអាជ្ញាធរមូលដ្ឋាន និងពីមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- របាយការណ៍សកម្មភាព ការរៀនសូត្រពីកសិករទៅកសិករជូនមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។

❖ **ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម/ភ្នាក់ងារផ្សព្វផ្សាយឃុំ**

- ជ្រើសរើសកសិករ គំរូ កសិករឆ្នើម កសិករគ្រូ
- អនុវត្តវិធីសាស្ត្រការរៀនសូត្រពីកសិករទៅកសិករ
- ធ្វើផែនការចំណាយ និងដឹកនាំសកម្មភាពការរៀនសូត្រពីកសិករទៅកសិករ ឲ្យស្របទៅនឹងគោលបំណងខាងលើបន្ទាប់ពីទទួលបានតម្រូវការដែលបានលើកឡើងក្នុងវេទិកាពហុពាក់ព័ន្ធ ឬការប្រជុំបណ្តុំអាជីវកម្ម
- ទទួលបានថវិកាបុរេប្រទានពីមន្ទីរកសិកម្ម ដើម្បីអនុវត្តសកម្មភាពនេះ និងត្រូវយកវិក្កិយបត្រដើម្បីទូទាត់ជាមួយមន្ទីរកសិកម្ម
- ចូលរួមប្រជុំជាមួយប្រចាំត្រីមាសរវាង មន្ត្រីការិយាល័យកសិកម្មស្រុក កសិករគ្រូ អាជ្ញាធរមូលដ្ឋាន
- បញ្ចូលទិន្នន័យលទ្ធផល ការរៀនសូត្រពីកសិករទៅកសិករ ទៅក្នុង tablets.
- របាយការណ៍លទ្ធផលការអនុវត្តសកម្មភាព ការសិក្សាពីកសិករទៅកសិករជូនការិយាល័យកសិកម្មស្រុក។

- ❖ **តួនាទី និងការទទួលខុសត្រូវរបស់កសិករគំរូ**
  - ចូលរួមរៀនសូត្របច្ចេកទេស និងសកម្មភាពផ្សេងៗតាមការកំណត់របស់កម្មវិធី
  - ធ្វើផែនការអនុវត្តបច្ចេកទេសថ្មីដែលបានបណ្តុះបណ្តាល
  - កត់ត្រាលើសៀវភៅកត់ត្រាសកម្មភាពសាលារៀនស្រែកសិករឲ្យបានច្បាស់លាស់ និងជាប្រចាំ
  - ចែករំលែកបទពិសោធន៍ និងចំណេះដឹងបច្ចេកទេសដល់ក្រុមនិងកសិករជជិតខាងដូចជា៖
    - ទិវាបង្ហាញ
    - ការប្រជុំក្រុមធំ ក្រុមតូច
    - ការអនុវត្តប្រចាំថ្ងៃ
  - ផ្លាស់ប្តូរបទពិសោធន៍ជាមួយសមាជិកក្រុមអំពី៖
    - ការផលិត
    - ការកត់ត្រាចំណូល ចំណាយ និងចំណេញ
  - ចែករំលែក និងផ្ទេរបន្តសមិទ្ធផលរបស់ក្រុម ជាមួយសមាជិកក្រុមតាមគោលការណ៍ឯកភាពរបស់ក្រុមដែលបានចែង
  - ទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ និងស្ថាប័នជំនាញ វិស័យឯកជន ឬអង្គការនានាពាក់ព័ន្ធ
  - រាយការណ៍ប្រចាំខែរាល់គ្រប់សកម្មភាពការងារក្នុងក្រុម ឬផ្ទាល់មាត់ករណីមានបញ្ហាកើតឡើងជាយថាហេតុ ដល់ភ្នាក់ងារផ្សព្វផ្សាយ និងអ្នកបច្ចេកទេសកសិកម្ម។
- ❖ **តួនាទីកសិករឆ្នើម**
  - អនុវត្តបច្ចេកទេសថ្មីដែលបានរៀនរួចនៅក្នុងកសិដ្ឋានរបស់ខ្លួន
  - កត់ត្រា ចំណាយ-ចំណូល លើសៀវភៅកត់ត្រាការគ្រប់គ្រងអាជីវកម្មកសិកម្ម
  - សហការជាមួយភ្នាក់ងារផ្សព្វផ្សាយឃុំ និងមន្ត្រីកសិកម្មស្រុកក្នុងការបណ្តុះបណ្តាលក្រុមកសិករដឹកនាំការធ្វើទិវាបង្ហាញ វេទិកាកសិករ ទស្សនៈកិច្ចកសិកដ្ឋានដែលទទួលជោគជ័យ ចងក្រងជាបណ្តុំផលិត និងការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅទីផ្សារ
  - ចុះតាមដានការអនុវត្តផ្ទាល់ និងផ្តល់ការណែនាំដល់សមាជិកក្រុមដែលទទួលបានការបណ្តុះបណ្តាល
  - រាយការណ៍ជូនភ្នាក់ងារផ្សព្វផ្សាយឃុំ/ភ្នាក់ងារផ្សព្វផ្សាយ និងកសិកម្មស្រុក។
  - ប្រឹក្សាយោបល់ និងផ្តល់ការណែនាំដល់សមាជិកក្រុមដែលទទួលបានការបណ្តុះបណ្តាល។
- ❖ **តួនាទីកសិករគ្រូ**:
  - ជាអ្នកសម្របសម្រួល និងជួយក្នុងការចងក្រងក្រុម ការវាយតម្លៃតម្រូវការកសិករ ទិវាស្រែកសិករបង្កើតថ្នាលបណ្តុះកូនឈើរបស់សហគមន៍ ទស្សនៈកិច្ចសិក្សា
  - បង្កើតបណ្តុំក្រុមផលិតសម្រាប់ទីផ្សារ
  - បណ្តុះបណ្តាលកសិករក្រុមផលិតដើម្បីចែករំលែកពីភាពជោគជ័យនៃការអនុវត្តធុរកិច្ចកសិកម្ម
  - ជួយសម្របសម្រួលក្នុងការចងក្រង/បណ្តាញនៃការរៀនសូត្រពីកសិករទៅកសិករនៅថ្នាក់ឃុំ
  - បម្រើសេវាកម្មបណ្តុះបណ្តាលផ្សព្វផ្សាយបច្ចេកទេសកសិកម្ម GAP ដែលកសិករត្រូវការ (ដើរតួនាទីជាកសិករគ្រូ)
  - ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដល់កសិករជិតខាង ដែលមានចំណាប់អារម្មណ៍ក្នុងម្នាក់ចំនួន ៥នាក់ និងបង្កើតជាបណ្តុំផលិត (Business Cluster)
  - ការរៀបចំផែនការផលិតកម្ម និងផែនការអាជីវកម្ម

- ប្រមូល និងចែករំលែកព័ត៌មានទីផ្សារផលិតផលកសិកម្ម ដល់បណ្តុំផលិតផលកសិកម្ម
- សម្របសម្រួលទំនាក់ទំនងរវាង បណ្តុំផលិត និងអ្នកទិញផលិតផល
- តាមដាន និងបង្រៀនបន្ថែមដល់ក្រុមកសិករគោលដៅ
- ផលិតជីកំប៉ុស្តិ៍គោក និងជីកំប៉ុស្តិ៍ទឹកសម្រាប់លក់ និងផលិតផលកសិកម្មដើម្បីភ្ជាប់ទៅទីផ្សារ
- ការចូលរួមប្រជុំប្រចាំត្រីមាសជាមួយអាជ្ញាធរមូលដ្ឋាន ភ្នាក់ងារផ្សព្វផ្សាយឃុំ/ភ្នាក់ងារផ្សព្វផ្សាយ និងកសិកម្មស្រុក ដើម្បីពិភាក្សាពី បញ្ហាដែលទាក់ទងនិង ការតាមដានក្រុមកសិករ និងបណ្តាញនៃការរៀនសូត្រពីកសិករទៅកសិករ។

## ១០. ការតាមដាន និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គឺជាផ្នែកមួយសំខាន់ក្នុងចំណោមផ្នែកផ្សេងៗទៀត នៃការគ្រប់គ្រងការអនុវត្តសកម្មភាព ការរៀនសូត្រពីកសិករទៅកសិករ គឺដើម្បីធានាថា និងសម្រេចបាននូវទិសដៅ គោលបំណងរបស់គោលការណ៍ណែនាំ បណ្តាញការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលទៅកាន់ទីផ្សារដែរ។ កិច្ចការងារនេះ វាមិនត្រឹមតែអាចជួយបង្កើតគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធិផលនៃការអនុវត្តគោលការណ៍ណែនាំការរៀនសូត្រពីកសិករទៅកសិករ ឬកម្មវិធីទាំងមូលប៉ុណ្ណោះទេ វាថែមទាំងអាចឆ្លុះបញ្ចាំង ពីគណនេយ្យភាព តម្លាភាព មេរៀន និងបទពិសោធន៍ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យកសិកម្មស្រុកផងដែរ។ លទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអាចផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់អ្នកធ្វើការសម្រេចចិត្ត ជាពិសេសថ្នាក់ដឹកនាំមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ លេខាធិការដ្ឋានកម្មវិធី ASPIRE នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម និងនាយកដ្ឋានផែនការស្ថិតិ មានវិធានការណ៍ កែសម្រួលនៅចំណុចខ្វះខាតណាមួយដែលអាចកើតឡើងបានទាន់ពេលវេលា។

មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដែលមានមន្ត្រីតាមដាន និងវាយតម្លៃ និងមន្ត្រីបច្ចេកទេសកសិកម្ម ដែលទទួលបន្ទុក សកម្មភាព ការរៀនសូត្រពីកសិករទៅកសិករ នឹងចូលរួមតាមដាន និងវាយតម្លៃជាប្រចាំផងដែរ ទៅលើផែនការសកម្មភាពរបស់ខ្លួន សំខាន់ផ្តោតលើ លទ្ធផល នៃការអនុវត្តប្រចាំឆ្នាំ ដើម្បីធានាថាផែនការអន្តរាគមន៍ និងលទ្ធផលសម្រេចបាន ឆ្លើយតបទៅនឹង ទិសដៅ គោលដៅ វិធីសាស្ត្រ លទ្ធផលរំពឹងទុក សកម្មភាព និងសូចនាករដែលបានកំណត់។

មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ត្រូវធានាថាការផ្តល់ថវិកាកម្មវិធីរបស់កម្មវិធី ASPIRE ត្រូវតែចូលរួមប្រើប្រាស់ថវិកាទៅលើការអនុវត្តសកម្មភាព ការរៀនសូត្រពីកសិករទៅកសិករ។ លេខាធិការដ្ឋានកម្មវិធី ASPIRE ត្រូវមានទិន្នន័យ តាមដាន និងវាយតម្លៃ និងបង្កើតសូចនាករវាស់វែងលទ្ធផលសកម្មភាព បណ្តាញការរៀនសូត្រពីកសិករទៅកសិករ ចំណែកមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់យកប្រព័ន្ធតាមដាន និងវាយតម្លៃដែលមានសមាសធាតុ និងសកម្មភាពដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផល នៃការអនុវត្ត
- ចុះតាមដាន លើការអនុវត្តផែនការសកម្មភាពជាប្រចាំ នៅតាមតំបន់គោលដៅ ដែលបានអនុវត្តកម្មវិធី
- រៀបចំរបាយការណ៍វឌ្ឍនភាព ប្រចាំខែ ត្រីមាស ៩ខែ និងប្រចាំឆ្នាំ
- រៀបចំរបាយការណ៍ ចុះតាមដាន ឬ ត្រួតពិនិត្យផ្ទាល់នៅមូលដ្ឋាន
- ប្រជុំឆ្លុះបញ្ចាំងលើរបាយការណ៍ ដែលទទួលបាន មកពីការចុះត្រួតពិនិត្យ និងវាយតម្លៃរួម ពីមន្ត្រីបច្ចេកទេសថ្នាក់ខេត្ត ភ្នាក់ងារផ្សព្វផ្សាយថ្នាក់ស្រុក និងឃុំ។

ផ្អែកលើរបាយការណ៍ វឌ្ឍនភាព និងសមិទ្ធិផលសម្រេចបាន ក្នុងការអនុវត្តនេះ នឹងត្រូវរៀបចំបូកសរុបនិងរាយការណ៍ជូន មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ លេខាធិកាដ្ឋានកម្មវិធី ASPIRE និងចម្លងជូន នាយកដ្ឋានផែនការស្ថិតិ និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ។ ក្រៅពីនេះមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទនឹងរាយការណ៍ជូនទៅ កសិកម្មស្រុក និងអាជ្ញាធរមូលដ្ឋាន (សាលាស្រុក និងក្រុមប្រឹក្សាឃុំ)។

### លំហូរនៃរបាយការណ៍




## ១១. សេចក្តីសន្និដ្ឋាន

ការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលទៅកាន់ទីផ្សារ ត្រូវបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ។ ការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលទៅកាន់ទីផ្សារ អាចដំណើរការបានជោគជ័យអាស្រ័យទៅលើកសិករគ្រូ និងការគាំទ្រពីដៃគូរពាក់ព័ន្ធដូចជាភ្នាក់ងារផ្សព្វផ្សាយឃុំ/ភ្នាក់ងារផ្សព្វផ្សាយ មន្ត្រីផ្សព្វផ្សាយកសិកម្ម ស្រុក ខេត្ត វិស័យឯកជន អង្គការស្ថាប័នពាក់ព័ន្ធនានា និងកសិករ ។ កសិករគ្រូ ធ្វើការងារដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងប្រើប្រាស់ឱកាសសម្រាប់ការបង្កើនហិរញ្ញវត្ថុ ។

វិធីសាស្ត្រការផ្សព្វផ្សាយពីកសិករទៅកសិករ មានប្រសិទ្ធិភាពជាងការផ្សព្វផ្សាយដោយមន្ត្រីផ្សព្វផ្សាយពីព្រោះវាជាវិធីសាស្ត្រផ្សព្វផ្សាយដែលធ្វើឡើងដោយកសិករ ដែលឈរលើការអនុវត្តន៍ជាក់ស្តែងក្នុងសហគមន៍របស់គាត់ ដែលធ្វើឲ្យកសិករដ៏ទៃទៀតមានទំនុកចិត្ត ក្នុងការអនុវត្តន៍តាម។ ហេតុដូច្នេះ ការរៀនសូត្រពីកសិករទៅកសិករ គឺឆ្លើយតបតាមតម្រូវការមូលដ្ឋាន។

ដើម្បីឲ្យបណ្តាញការរៀនសូត្រពីកសិករទៅកសិកររឹងមាំ និងគង់វង្សយូរអង្វែង កសិករគួរត្រូវបានផ្តល់ឱកាសឲ្យចូលរួម វេទិកាផ្សព្វផ្សាយកសិកម្ម ពិព័រណ៍សម្ភារៈកសិកម្ម (ថ្នាក់កណ្តាល និងថ្នាក់ខេត្ត) និងបង្កើតឲ្យមានការសហការជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍនកសិកម្ម និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម....។

សកម្មភាពទាំងអស់នេះហើយដែលអាចជួយធានាថា អ្នកពាក់ព័ន្ធទាំងអស់អាចជួយបន្តគាំទ្រដំណើរការរៀនសូត្រពីកសិករទៅកសិករ ផ្តល់នូវព័ត៌មានថ្មីៗធ្វើឲ្យមានប្រព័ន្ធផ្សព្វផ្សាយមានប្រសិទ្ធិភាព និងប្រព័ន្ធការផ្សព្វផ្សាយពីកសិករទៅកសិករមាននិរន្តរភាព។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ : វេទិកាកសិករថ្នាក់ឃុំ

| កាលបរិច្ឆេទ/ម៉ោង | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០-០៨:១៥ | ការបង្ហាញពីគោលបំណង និងដំណើរការវេទិកាកសិករ | ភ្នាក់ងារផ្សព្វផ្សាយកសិកម្មស្រុក |
| ០៨:១៥-០៨:២៥ | មតិស្វាគមន៍របស់អាជ្ញាធរមូលដ្ឋាន | មេឃុំ ឬតំណាង |
| ០៨:២៥-០៩:២៥ | បទបង្ហាញរបស់កសិករ ពីបទពិសោធន៍ ភាពជោគជ័យ បញ្ហាពីទីផ្សារ ការអនុវត្តអាជីវកម្មកសិកម្ម ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ប្រព័ន្ធផ្តល់ព័ត៌មានជាមុន និងផែនការត្រៀមបង្ការគ្រោះមហន្តរាយ | កសិករឆ្នើម/កសិករគ្រូ |
| ០៩:២៥-១០:២៦ | បទបង្ហាញរបស់ផ្នែកឯកជន ពីចំណេះដឹង បញ្ហាប្រឈម ភាពជោគជ័យ ក្នុងការអនុវត្តអាជីវកម្ម | ផ្នែកឯកជន |
| ១០:២៥-១១:០០ | សំណួរ ចម្លើយ និងការពិភាក្សា | ភ្នាក់ងារផ្សព្វផ្សាយឃុំ/និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មស្រុក |
| ១១:០០-១១:២០ | មតិបូកសរុប និងសង្ខេបលទ្ធផល | ប្រធានការិយាល័យកសិកម្មស្រុក |
| ១១:២០-១១:៣៥ | មតិចាប់អារម្មណ៍ ការផ្តាំផ្ញើររបស់គណៈអធិបតី និងបិទកម្មវិធីវេទិកា | ក្រុមប្រឹក្សាឃុំ |

**អ្នកចូលរួមមាន៖**

- អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ អ្នកលក់ធាតុចូលកសិកម្ម ឈ្មួញកណ្តាល
- មន្ត្រីបច្ចេកទេសកសិកម្មខេត្ត ការិយាល័យកសិកម្មស្រុក
- ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ កិច្ចការនារីស្រុក/ឃុំ មេភូមិ
- ភ្នាក់ងារផ្សព្វផ្សាយឃុំ កសិករគ្រូ កសិករបណ្តុំអាជីវកម្ម។

**វាគ្មិន៖**

- មន្ត្រីបច្ចេកទេសកសិកម្មខេត្ត/ស្រុក កសិករឆ្នើម/កសិករគ្រូ។

**រយៈពេលមួយព្រឹក ។**

**ឧបសម្ព័ន្ធទី ២ : វេទិកាធុរកិច្ចកសិកម្ម នៅថ្នាក់ខេត្ត**

| ពេលវេលា | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០-០៨:១៥ | ការចុះឈ្មោះសិក្ខាកាម | មន្ត្រីអនុវត្តគម្រោង |
| ០៨:១៥-០៨:៣០ | ប្រកាសហេតុ ភ្ញៀវចូលរួម គណៈអធិបតី គោរពភ្លេងជាតិ | មន្ត្រីអនុវត្តគម្រោង |
| ០៨:៣០-០៨:៤៥ | មតិសំណេះសំណាល របស់ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ០៨:៤៥-០៩:០០ | មតិសំណេះ និងបើកអង្គពិធី ដោយឯកឧត្តម អភិបាលខេត្ត | ឯកឧត្តម្ភ អភិបាលខេត្ត |
| ០៩:០០-០៩:១៥ | បទបង្ហាញ ស្តីពីគោលបំណងនៃសិក្ខាសាលា វេទិកាអាជីវកម្មកសិកម្ម | មន្ត្រីទទួលបន្ទុកការរៀនសូត្រពីកសិករទៅកសិករ |
| ០៩:១៥-០៩:៤៥ | បទបង្ហាញ ពីគោលបំណង និងដំណើរការ នៃការរៀនសូត្រពីកសិករទៅកសិករ និងការតភ្ជាប់កសិផលទៅកាន់ទីផ្សារ។<br>**សំណួរ-ចម្លើយ** | មន្ត្រីទទួលបន្ទុកការរៀនសូត្រពីកសិករទៅកសិករ |
| ០៩:៤៥-១០:០០ | **អាហារសម្រន់ និងទស្សនកិច្ចពិព័ណ៌កសិកម្ម** | |
| ១០:០០-១០:២០ | បទបង្ហាញ ពីព័ត៌មានទីផ្សារកសិផល និងការគាំទ្រផលិតផលកសិកម្ម<br>**សំណួរ-ចម្លើយ** | តំណាងមន្ទីរពាណិជ្ជកម្មខេត្ត |
| ១០:២០-១០:៤០ | បទបង្ហាញ របស់ក្រុមហ៊ុនផ្គត់ផ្គង់ធាតុចូលកសិកម្ម (ពូជបន្លែ ជីគីមី ជីសរីរាង្គ វ៉ាក់សាំងសត្វ ថ្នាំព្យាបាល និងសម្ភារៈកសិកម្មផ្សេងៗ...)<br>**សំណួរ-ចម្លើយ** | ក្រុមហ៊ុនផ្គត់ផ្គង់ធាតុចូល |
| ១០:៤០-១១:០០ | បទបង្ហាញពីទីផ្សារសត្វ<br>**សំណួរ-ចម្លើយ** | សហគមន៍កសិកម្ម ឬបណ្តុំផលិតអាជីវកម្មកសិកម្ម |
| **១១:០០-១៣:៣០** | **សម្រាកពិសារបាយថ្ងៃត្រង់** | |
| ១៣:៣០-១៤:០០ | បទបង្ហាញពីទីផ្សារបន្លែ<br>**សំណួរ-ចម្លើយ** | សហគមន៍កសិកម្ម ឬបណ្តុំផលិតអាជីវកម្មកសិកម្ម |
| ១៤:០០-១៤:២០ | បទបង្ហាញពីទីផ្សារស្រូវ<br>**សំណួរ-ចម្លើយ** | សហគមន៍កសិកម្ម ឬបណ្តុំផលិតអាជីវកម្មកសិកម្ម |
| ១៤:២០-១៤:៤៥ | បទបង្ហាញ ស្តីពីគោលការណ៍កម្ចីធ្វើឥណទានជាមួយសហគមន៍កសិកម្ម ក្រុមកសិករ<br>**សំណួរ-ចម្លើយ** | តំណាងធនាគារ និង តំណាងមីក្រូហិរញ្ញវត្ថុ |
| ១៤:៤៥-១៥:០០ | បទបង្ហាញ ស្តីពីកសិកម្មតាមកិច្ចសន្យា<br>**សំណួរ-ចម្លើយ** | ការិយាល័យ កសិឧស្សាហកម្ម |

| ១៥:០០-១៥:១៥ | អាហារសម្រន់ និងទស្សនកិច្ចពិព័ណ៌កសិកម្ម | |
|---|---|---|
| ១៥:១៥-១៥:៣៥ | បទបង្ហាញ ស្តីពីបទពិសោធន៍ ក្នុងការធ្វើផលិតកម្មតាមកិច្ចសន្យា<br>**សំណួរ-ចម្លើយ** | សហគមន៍កសិកម្ម ឬបណ្តុំអាជីវកម្មកសិកម្ម |
| ១៥:៣៥-១៦:១៥ | **ពិភាក្សាក្រុម ស្តីពី៖**<br>**ក្រុមទី១៖** តើធ្វើដូចម្តេចដើម្បីនាំផលិតផលទៅកាន់ទីផ្សារបានប្រកបដោយជោគជ័យ?<br>**ក្រុមទី២៖** ប្រសិនបើក្រុមផលិតរបស់អ្នកជួបប្រទះនូវឧបសគ្គក្នុងការនាំផលិតផលទៅកាន់ទីផ្សារតើអ្នកមានដំណោះស្រាយដូម្តេចខ្លះ?<br>**ក្រុមទី៣៖** ការពិភាក្សាពី ដំណើរការធ្វើកសិកម្មតាមកិច្ចសន្យា? (ជោគជ័យ ឧបសគ្គ និងដំណោះស្រាយ)? | មន្ត្រីទទួលបន្ទុកការរៀនសូត្រពីកសិករទៅកសិករ |
| ១៦:១៥-១៦:៣០ | បទបង្ហាញលទ្ធផលពិភាក្សាក្រុម | ក្រុមពិភាក្សា |
| ១៦:៣០-១៦:៤៥ | បូកសរុប របាយការណ៍លទ្ធផលវេទិកាអាជីវកម្មកសិកម្ម | មន្ត្រីទទួលបន្ទុកការរៀនសូត្រពីកសិករទៅកសិករ |
| ១៦:៤៥-១៧:០០ | មតិបិទលទ្ធផលវេទិកាអាជីវកម្ម | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

**អ្នកចូលរួមមាន៖**

- អភិបាលខេត្តឬតំណាង មន្ទីរពាណិជ្ជកម្ម សភាពាណិជ្ជកម្មខេត្ត
- អង្គការមិនមែនរដ្ឋាភិបាលធ្វើការងារក្នុងវិស័យកសិកម្ម
- អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អ្នកប្រមូលទិញ សណ្ឋាគារ កាស៊ីណូ ក្រុមហ៊ុនប្រមូលទិញឈ្មួញកណ្តាល
- មន្ត្រីបច្ចេកទេសកសិកម្មថ្នាក់ខេត្ត ការិយាល័យកសិកម្មស្រុក ភ្នាក់ងារផ្សព្វផ្សាយឃុំ
- ប្រធានបណ្តុំអាជីវកម្មកសិកម្ម កសិករគ្រូ សហគមន៍កសិកម្ម
- ស្ថាប័នមីក្រូហិរញ្ញវត្ថុ
- មន្ទីរកិច្ចការនារី

**វាគ្មិន៖**

- មន្ត្រីបច្ចេកទេសកសិកម្មខេត្ត
- កសិករជោគជ័យ (សហគមន៍កសិកម្ម បណ្តុំអាជីវកម្មកសិកម្ម...)
- តំណាងក្រុមហ៊ុន/អ្នកប្រមូលទិញ
- តំណាងក្រុមហ៊ុន/អ្នកលក់ធាតុចូលកសិកម្ម
- មន្ទីរពាណិជ្ជកម្ម ។

**រយៈពេលមួយថ្ងៃ ។**

**ឧបសម្ព័ន្ធទី៣: សកម្មភាព និងតម្រូវការប៉ាន់ស្មាន ថវិកា សម្ភារៈសម្រាប់ សកម្មភាពការរៀនសូត្រពីកសិករទៅកសិករ**

**១.បណ្តុះបណ្តាលមន្ត្រីកសិកម្មស្រុកនិងភ្នាក់ងារផ្សព្វផ្សាយឃុំ ពីវិធីសាស្ត្រ និងដំណើរការអនុវត្តការរៀនសូត្រពីកសិករទៅកសិករ (នៅថ្នាក់ខេត្ត)**

- អាហារសម្រន់
- ប្រាក់ឧបត្ថម្ភមន្ត្រីកសិកម្មស្រុក និងថ្លៃធ្វើដំណើរ
- ប្រាក់ឧបត្ថម្ភភ្នាក់ងារផ្សព្វផ្សាយ និងថ្លៃធ្វើដំណើរ
- សម្ភារៈបណ្តុះបណ្តាល
- បដា។

**២.ជ្រើសរើសកសិករគំរូ (នៅតាមភូមិនីមួយៗ)**

**២.១.ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករគំរូ**

- អាហារសម្រន់
- ប្រាក់ឧបត្ថម្ភភ្នាក់ងារផ្សព្វផ្សាយចុះជ្រើសរើសកសិករ
- សម្ភារៈប្រជុំ។

**២.២.បណ្តុះបណ្តាល និងកសាងសមត្ថភាពកសិករគំរូ**

- អាហារសម្រន់
- សម្ភារៈបណ្តុះបណ្តាល
- ប្រាក់ឧបត្ថម្ភភ្នាក់ងារផ្សព្វផ្សាយ
- ថ្លៃឈ្នួលគ្រូបណ្តុះបណ្តាល។

**៣.ជ្រើសរើសកសិករឆ្នើម (នៅតាមឃុំនីមួយៗ)**

**៣.១.ប្រជុំឆ្លុះបញ្ចាំង និងជ្រើសរើសកសិករឆ្នើម (១នាក់/ឃុំ)**

- អាហារសម្រន់
- សម្ភារៈប្រជុំ
- ប្រាក់ឧបត្ថម្ភភ្នាក់ងារផ្សព្វផ្សាយ ចុះជ្រើសរើសកសិករ។

**៣.២.បណ្តុះបណ្តាលកសិករឆ្នើមឲ្យក្លាយជាកសិករគ្រូ**

- អាហារសម្រន់
- សម្ភារៈបណ្តុះបណ្តាល
- ថ្លៃធ្វើដំណើរសម្រាប់កសិករ
- ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (DSA)ភ្នាក់ងារផ្សព្វផ្សាយ
- ថ្លៃឈ្នួលគ្រូបណ្តុះបណ្តាល
- បដា។

**៤.នាំកសិករចាប់អារម្មណ៍/ឬកសិករធ្វើធុរកិច្ចកសិកម្មតែមិនទាន់ជោគជ័យទៅ ទស្សនៈកិច្ចសិក្សាពីកសិករដែលជោគជ័យ(កសិករឆ្នើម ឬកសិករគ្រូ)លើការអនុវត្តធុរកិច្ចកសិកម្ម**

- អាហារសម្រន់
- ថ្លៃធ្វើដំណើរសម្រាប់កសិករ
- ថ្លៃឈ្នួលរថយន្ត

- ប្រាក់ឧបត្ថម្ភភ្នាក់ងារផ្សព្វផ្សាយ
- វត្ថុអនុស្សាវរីយ៍។

**៥.ជ្រើសរើស និងកំណត់កសិករស្ម័គ្រចិត្តធ្វើធុរកិច្ចកសិកម្មជាមួយកសិករគ្រូ**

**៥.១. ប្រជុំផ្សព្វផ្សាយ និងជ្រើសរើសកសិករស្ម័គ្រចិត្តអនុវត្តកសិធុរកិច្ចកសិកម្ម (៤ឬ ៨នាក់/ឃុំ)**

- អាហារសម្រន់
- សម្ភារៈប្រជុំ
- ប្រាក់ឧបត្ថម្ភភ្នាក់ងារផ្សព្វផ្សាយ ចុះជ្រើសរើសកសិករស្ម័គ្រចិត្ត។

**៥.២. ផ្តល់ទុនគាំទ្រការអនុវត្តន៍កសិធុរកិច្ចកសិកម្ម**

- ផ្តល់ទុនគាំទ្រការអនុវត្តកសិធុរកិច្ចរបស់សមាជិកម្នាក់ៗ (មានកញ្ចប់ថវិកា២០% នៃតម្លៃវិនិយោគសរុប ដែលអាចផ្តល់ជូនសមាជិកម្នាក់ៗ(បណ្តុំអាជីវកម្មកសិកម្ម) ដើម្បីទទួលយកនូវបច្ចេកវិទ្យាថ្មីទៅអនុវត្តតាម។

**៦. កសិករគ្រូបណ្តុះបណ្តាលកសិករដែលស្ម័គ្រចិត្តធ្វើធុរកិច្ចកសិកម្ម**

- អាហារសម្រន់
- សម្ភារៈបណ្តុះបណ្តាល
- ថ្លៃឈ្នួលបណ្តុះបណ្តាលរបស់កសិករគ្រូ
- ប្រាក់ឧបត្ថម្ភភ្នាក់ងារផ្សព្វផ្សាយឃុំ
- បដា។

**៧.វេទិកាកសិករថ្នាក់ឃុំ**

- អាហារសម្រន់ និងបាយថ្ងៃត្រង់
- ថ្លៃជួលរោង និងមេក្រូ
- ថ្លៃធ្វើដំណើរកសិករចូលរួម
- ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំចូលរួម/មេភូមិ និងថ្លៃធ្វើដំណើរ
- សម្ភារៈសិក្ខាសាលា
- ប្រាក់ឧបត្ថម្ភភ្នាក់ងារផ្សព្វផ្សាយ។

**៨.វេទិកាធុរកិច្ចកសិកម្មថ្នាក់ខេត្ត**

- អាហារសម្រន់ និងអាហារថ្ងៃត្រង់
- ថ្លៃជួលរោង និងមេក្រូ
- ប្រាក់ឧបត្ថម្ភកសិករចូលរួម និងថ្លៃធ្វើដំណើរ
- ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំចូលរួម/មេភូមិ និងថ្លៃធ្វើដំណើរ
- ប្រាក់ឧបត្ថម្ភ និងថ្លៃធ្វើដំណើរភ្នាក់ងារផ្សព្វផ្សាយឃុំ
- ប្រាក់ឧបត្ថម្ភ និងថ្លៃធ្វើដំណើរសម្រាប់កសិករ
- ប្រាក់ឧបត្ថម្ភ និងថ្លៃធ្វើដំណើរមន្ត្រីការិយាល័យកសិកម្មស្រុក
- សម្ភារៈសិក្ខាសាលា។

## ឧបសម្ព័ន្ធទី៤: ទម្រង់វាយតម្លៃកសិករឆ្នើម ក្លាយជាកសិករគ្រូ ក្នុងសកម្មភាពការរៀនសូត្រពីកសិករទៅកសិករ

### ១.ព័ត៌មានទូទៅ

| **អ្នកវាយតម្លៃ** | |
|---|---|
| កាលបរិច្ឆេទៈ | |
| ឈ្មោះអ្នកវាយតម្លៃ | |
| ឈ្មោះស្ថាប័ន និងអាសយដ្ឋានទំនាក់ទំនង អ្នកវាយតម្លៃ | |
| ឈ្មោះកសិករដែលត្រូវវាយតម្លៃ | |

### ២.លក្ខណៈវិនិច្ឆ័យ

| **លក្ខណៈវិនិច្ឆ័យ** | **ពិន្ទុសរុប ១០០** | | **បញ្ជាក់** |
|---|---|---|---|
| | **ពិន្ទុខ្ពស់បំផុត** | **ពិន្ទុផ្តល់** | |
| ១.ជាកសិករដែលជោគជ័យ ក្នុងការអនុវត្តធុរកិច្ចកសិកម្ម | ៣០ | | - អាចបង្កើត និងអនុវត្តផែនការអាជីវកម្មទទួលបានជោគជ័យ<br>- បានអនុវត្តបច្ចេកទេសថ្មីៗដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅក្នុងកសិដ្ឋានរបស់ខ្លួន<br>- មានការកត់ត្រា ចំណាយ-ចំណូល លើសៀវភៅកត់ត្រាការគ្រប់គ្រងអាជីវកម្មកសិកម្ម។ |
| ២.មានធនធាននឹងពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមកម្មវិធី | ៣០ | | - លះបង់ពេលវេលាក្នុងការចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់កសិករដ៏ទៃ<br>- មានកសិដ្ឋានក្នុងការអនុវត្តសកម្មភាពផ្សេងៗ (មាន់ ជ្រូក ដំណាំផ្សេង.......) |

| | | | |
|---|---|---|---|
| ៣.ជាកសិករមានគំនិតច្នៃប្រឌិតច្រើន | ២០ | | - បង្កើតឧបករណ៍ឬសម្ភារៈផ្សេងៗសម្រាប់អនុវត្តក្នុងកសិដ្ឋានរបស់ខ្លួន (ជីសរីរាង្គឧបករណ៍ស្រោចដំណាំ ថ្នាំពុលធម្មជាតិ ដំណាំអន្ទាក់.....)<br>- មានគំនិតស្រាវជ្រាវបច្ចេកទេសថ្មីៗ។ |
| ៤. មានភាពប៉ិនប្រសប់ក្នុងការប្រាស្រ័យទាក់ទង | ២០ | | - ការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅទីផ្សារ<br>- ទំនាក់ទំនងល្អជាមួយស្ថាប័នជំនាញ អ្នកលក់ធាតុចូល អ្នកទិញ ឬអង្គការនានាដែលពាក់ព័ន្ធ<br>- មានប្រជាប្រិយភាពក្នុងមូលដ្ឋាន<br>- ជួយកសិករដ៏ទៃពេលមានបញ្ហាក្នុងការធ្វើធុរកិច្ចកសិកម្ម។ |
| **ពិន្ទុសរុប** | **១០០** | | |

**កំណត់សំគាល់ផ្សេងទៀតៈពិន្ទុដែលអាចជាប់ជាកសិករឆ្នើមមានចាប់ពី ៧០ឡើងទៅ**

..........................................................................................................................................................

..........................................................................................................................................................

# ឯកសារយោង


១. The New Extensionist Learning Kit-global forum for rural advisory services, Switzerland, info@g-fras.org ។

២. គោលការណ៍ណែនាំស្តីពីការអនុវត្តន៍សកម្មភាព ការបញ្ជ្រាបពីកសិករទៅកសិករ គម្រោងអភិវឌ្ឍន៍កសិកម្ម និងជម្រុញកំណើនសេដ្ឋកិច្ច (PADEE)។

៣. សៀវភៅកត់ត្រា ភាពរីកចម្រើន មជ្ឈមណ្ឌលសិក្សាសហគមន៍ ២០១៦ គម្រោងអភិវឌ្ឍន៍កសិកម្ម និងជម្រុញកំណើនសេដ្ឋកិច្ច (PADEE)។

៤. Expanding PADEE's farmers managed Community Learning Centre Services in Cambodia, a pathway to innovation sustainable, October 2015-July 2016.

៥. Digital Green is working with mediators at the village level who use locally produced videos to motivate and train community members in adopting new and improved practices and techniques. (Instructional Videos on SLM practices, back ground research and user Manual, WOCAT for IFAD, June 2014).

៦. ពង្រាងគោលការណ៍ណែនាំ ការសិក្សាពីកសិករទៅកសិករ (F2F)-Dr.Gary Lake, April 2014

៧. ឯកសារសម្រាប់ការពិភាក្សា ការសិក្សាពីកសិករទៅកសិករ (F2F)-វិធីសាស្ត្រសិក្សាសម្រាប់កម្មវិធី ASPIRE ដោយ Dr.Jay Comment និង Yim Samnang ខែ កក្កដា ឆ្នាំ ២០១៦។

**បោះពុម្ពលើកទី១ ឆ្នាំ២០១៨ ដោយ**
កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ( ASPIRE )
អាសយដ្ឋាន ២០០ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
គេហទំព័រ WWW.ASPIREKH.ORG និង WWW.KHMERAGRI.INFO